ការបកប្រែក្រៅផ្លូវការ

ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ក្នុងឱកាសដ៏សោមនស្សរីករាយក្នុងឱកាសគម្រប់ខួបលើកទី ៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រ កម្ពុជា និងព្រះរាជាណាចក្រថៃ នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២០ នេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមបញ្ជាក់ថា ចំណងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ មានភាពស្អិតរមួត និងរឹងមាំ ជាមួយនឹងការពង្រីកកិច្ចសហប្រតិបត្តិការនិងការទទួលបាននូវផលប្រយោជន៍ទៅវិញទៅមកលើគ្រប់វិស័យ។

ក្នុងនាមជាមិត្តជិតខាងដ៏ល្អ តំបន់នានាតាមបណ្តោយព្រំដែនរបស់ប្រទេសយើងទាំងពីរ កំពុងតែទទួលបាននូវផ្លែផ្កានៃសុខសន្តិភាពនិងស្ថិរភាព រួមជាមួយនឹងការកើនឡើងជាលំដាប់នៃការធ្វើពាណិជ្ជកម្មឆ្លងដែន ដែលបានផ្តល់ការងារនិងលើកកម្ពស់ជីវភាពប្រជាជនរបស់ប្រទេសយើងទាំងពីរ។ គួរអោយកត់សម្គាល់ ពាណិជ្ជកម្មទ្វេភាគីរវាងព្រះរាជាណាចក្រយើងទាំងពីរមានការកើនឡើងយ៉ាងឆាប់រហ័ស ប្រហែលពី ៣០០ លានដុល្លារអាមេរិក កាលពី ២០ ឆ្នាំមុន ដល់ជាង ៩ ពាន់ លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៩។ បន្ថែមលើសពីនេះ ការវិនិយោគរបស់ប្រជាជនថៃក្នុងព្រះរាជាណាចក្រកម្ពុជាមានការកើនឡើងជាលំដាប់ផងដែរ ដែលរួមចំណែកយ៉ាងវិជ្ជមានដល់សេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ សេដ្ឋកិច្ចនៃប្រទេសថៃក៏ទទួលបាននូវផលប្រយោជន៍ជាអំណោយពីកម្លាំងពលកម្មកម្ពុជា និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផងដែរ។

យើងសម្រេចបាននូវវឌ្ឍនភាពដ៏សំខាន់ក្នុងការជំរុញការតភ្ជាប់។ ដូចជា ការសម្រេចបានជាដំបូងនូវ ស្ពានមិត្តភាពកម្ពុជា-ថៃ (ចំណុចស្ទឹងបត់-បានណងអៀន) ដែលតភ្ជាប់ខេត្តបន្ទាយមានជ័យនិងខេត្តស្រះកែវ។ លើសពីនេះ ការជួសជុលផ្លូវដែកដែលតភ្ជាប់សហគមន៍កម្ពុជានិងសហគមន៍ថៃជាច្រើន នឹងរួមចំណែកសម្រួលដល់លំហូរពាណិជ្ជកម្មអោយកាន់តែមានភាពប្រសើរឡើងនាពេលឆាប់ៗ ខាងមុខ។ ចំពោះវិស័យអប់រំវិញ

ទាំងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ បានក្លាយជាវិទ្យាស្ថានគំរូនៃភាពជោគជ័យសម្រាប់វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ទៀត ព្រមទាំងផ្តល់ឱកាសយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់យុវជនកម្ពុជាដើម្បីសម្រេចបាននូវភាពជោគជ័យ។ នាពេលថ្មីៗ នេះ យើងបានរួមសហការគ្នាយ៉ាងជិតស្និទ្ធដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើសេដ្ឋកិច្ចនិងសង្គមរបស់យើង។ ហើយនេះ ជាការត្រួសត្រាយផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានាទាំងនៅក្នុងតំបន់និងសកលលោក នាពេលអនាគត។

តាងនាមអោយរាជរដ្ឋាភិបាល និងប្រជាជនថៃ ខ្ញុំសូមសម្តែងនូវការជូនពរយ៉ាងកក់ក្តៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** និងចំពោះប្រជាជនកម្ពុជា ក្នុងឱកាសដ៏សោមនស្សរីករាយក្នុងឱកាសគម្រប់ខួបលើកទី ៧០ នៃការបង្កើតទំនាក់ទំនងការទូតនិងការសម្រេចបាននូវវឌ្ឍនភាពដ៏គួរអោយកត់សម្គាល់ក្នុងនាមជាមិត្តជិតខាងនិងជាដៃគូក្នុងតំបន់ដ៏ល្អ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា មិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និងថៃមានភាពរឹងមាំ និងឋិតថេរ។ លើសពីនេះ ប្រជាជនរបស់យើង ជាពិសេសយុវជនជំនាន់ក្រោយនឹងនៅតែបន្តការសហការរួមគ្នា ឆ្ពោះទៅអនាគតដែលកាន់តែល្អប្រសើរ ដើម្បីសន្តិភាព វិបុលភាព និងការអភិវឌ្ឍនរួម។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

**ឯកឧត្តម នាយឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ**